ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមករា និងទិសដៅការងារខែកុម្ភៈ ឆ្នាំ២០១៣

នៅក្នុងខែមករា ឆ្នាំ២០១៣នេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបើកទំព័រថ្មីលើការគ្រប់គ្រងវិន័យ និងការគ្រប់គ្រងការងារតាមបែបបទ និងនីតិវិធីការងារថ្មី ព្រមទាំងបានពង្រឹងពង្រីកទំនាក់ទំនងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីដកស្រង់បទពិសោធន៍លើការងារសភា ទាក់ទាញរកជំនួយសម្រាប់អភិវឌ្ឍសមត្ថភាពដល់មន្ត្រី និងអភិវឌ្ឍព្រឹទ្ធសភាឲ្យកាន់តែល្អប្រសើរ។

## ១.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានចាត់ចែងរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចូលរួមប្រជុំពិភាក្សាការងារជាមួយឯកឧត្តម លោកជំទាវ ជាប្រធានគណៈកម្មការនានា ជួបពិភាក្សាជាមួយភ្ញៀវជាតិ អន្តរជាតិ និងបានអញ្ជើញចូលរួមប្រជុំគណៈកម្មការអចិន្ត្រៃយ៍សមាគមអគ្គលេខាធិការសភាប្រើភាសាបារាំង ព្រមទាំងបានដឹកនាំកិច្ចប្រជុំការងារផ្សេងៗ ចំនួន១២លើក និងបានពិនិត្យសម្រេចលើឯកសារផ្សេងៗចំនួន៥៦២ច្បាប់ ។

-បានទទួលសេចក្តីព្រាងច្បាប់ពីរដ្ឋសភា ចំនួន០២ បានចម្លងចែកជូនគ្រប់សមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងបានសិក្សាវិភាគ និងធ្វើរបាយការណ៍ជូនគណៈកម្មការជំនាញ ។

-បានរៀបចំពិធីជំនួបសម្តែងការគួរសម រវាង **ឯកឧត្តម ទេព ងន** អនុប្រធានទី២ ព្រឹទ្ធសភា ជាមួយ **លោកជំទាវ ង្វៀន ធីថាញ់ហ័រ** ប្រធានសហព័ន្ធនារីវៀតណាម និងបានរៀបចំបែបបទជូនទទួល និងអមដំណើរថ្នាក់ដឹកនាំសមាជិក សមាជិកាព្រឹទ្ធសភា បំពេញទស្សនកិច្ច ចូលរួមមហាសន្និបាត កិច្ចប្រជុំនានា ទាំងក្នុង និងក្រៅប្រទេស ចំនួន០៣លើក ។

-បានសហការជាមួយសប្បុរសជនវៀតណាម ដើម្បីចែកអំណោយជូនបងប្អូនប្រជាពលរដ្ឋក្រីក្រចំនួន៨០០នាក់ នៅឃុំរាំងពិល ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ ។

-រៀបចំបន្ថែមលើតម្លៃសន្ទស្សន៍ប្រាក់បៀវត្ស ប្រាក់សង្គមកិច្ច និងប្រាក់ឧបត្ថម្ភបុណ្យចូល



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

ឆ្នាំ និងបុណ្យភ្ជុំ ។ ថតចម្លងឯកសារ ចំនួន១៣៨សំណើ និងចងក្រងឯកសារជាសៀវភៅចំនួន១៤០ក្បាល ដោះស្រាយសម្ភារ និងសំណើថវិកា ចំនួន២៤៩សំណើ ព្រមទាំងផ្តល់សេវាដឹកជញ្ជូនចំនួន១១៤លើក។

-ត្រួតពិនិត្យ បិទលេខកូដ និងប្រគល់សម្ភារការិយាល័យចំនួន០៤គ្រឿង ។ តម្លើង បញ្ចូលហ្គាស ជួសជុល ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនថតចម្លង ទូទឹកកក ទូរស័ព្ទ កៅអីវិលធំ សោគុ ឌីសង់ទ័របន្ទប់ទឹក ប្តូរអំពូល ព្រីកុងតាក់ ចំនួន៨៩គ្រឿង។

-បានបើកវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន០៨វគ្គ ចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេសចំនួន០៤វគ្គ និងបានធ្វើលិខិតទៅសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្នើសុំបញ្ចូលមន្ត្រីចំនួន០៦រូប ចូលរួមវគ្គបកប្រែភាសាវៀតណាម ។

-អង្គភាពសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា បានចាត់កងកម្លាំងការពារសន្តិសុខ សណ្តាប់ធ្នាប់ ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗ ចំនួន០៧លើក។

-បានធ្វើ និងផ្សព្វផ្សាយរបាយការណ៍ និងសម្រង់ស្ថិតិស្តីពីលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងព្រឹទ្ធសភា ចំនួន២៦០ច្បាប់។

-យកព័ត៌មាន និងថតសកម្មភាពការងាររបស់ព្រឹទ្ធសភា និងពិធីផ្សេងៗសរុបចំនួន១៧លើក បានបោះពុម្ពប្រតិទិនផែនការខែចំនួន២៣០ច្បាប់ និងបានរៀបចំពិព័ណ៌រូបភាព ផ្សព្វផ្សាយដល់សាធារណជន ព្រមទាំងធ្វើព្រឹត្តិបត្រព័ត៌មានប្រចាំថ្ងៃ (ព័ត៌មានជាតិ តំបន់ និងអន្តរជាតិ ) ចំនួន៧៩៥អត្ថបទ។

-ជួសជុលកុំព្យូទ័រ បញ្ចូលកម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធីខ្មែរ Unicode, Office សរុប ចំនួន៣៦គ្រឿង ។ ស្រាវជ្រាវកម្មវិធី ចងក្រងគន្លឹះកុំព្យូទ័រចំនួន១៤កម្មវិធី។ Upload ព័ត៌មាន និងឯកសារផ្សេងៗចំនួន៣១ប្រធានបទ និងបង្ហោះក្នុងវិបសាយ ចំនួន២១ប្រធានបទ។

-ទទួលអ្នកចូលអានសៀវភៅនៅក្នុងបណ្ណាល័យ ចំនួន៧៥៤នាក់ និងបានទទួលឯកសារសៀវភៅព្រឹត្តិបត្រកាសែត និងទស្សនាវដ្តី ចំនួន៨៤ច្បាប់ ៥៥ក្បាល ។ បោះត្រាសៀវភៅ និងបិទប័ណ្ណខ្ចីសងលើសៀវភៅ ចំនួន៣១៤ក្បាល បញ្ចូលសៀវភៅជាភាសាអង់គ្លេសក្នុងកម្មវិធីបណ្ណាល័យខ្ញុំ ចំនួន៣៥៧ក្បាល ចូលក្នុងបញ្ជីចំនួន១២៥ក្បាល ដាក់ក្រប ប្តូរ និងដាក់លេខកូដសៀវភៅ ចំនួន៣៣៨ក្បាល។

-បានទទួលពាក្យបណ្តឹងចំនួន០៣ករណី ទទួលលិខិតអន្តរាគមន៍លើពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋពីគណៈកម្មការទី១ទៅអភិបាលខេត្តប៉ៃលិន កំពត រតនគិរី និងខេត្តក្រចេះ ចំនួន០៤ករណី

ករណី ព្រមទាំងតាមដាន និងផ្តល់ព័ត៌មានអំពីចំណាត់ការពាក្យបណ្តឹងជូនម្ចាស់បណ្តឹង ចំនួន០៨ករណី ។ បានទទួល និងផ្ញើលិខិតបេសកកម្ម លិខិតអនុញ្ញាតច្បាប់ លិខិតឧទ្ទេសនាម និងកំណត់បង្ហាញលើលិខិតផ្សេងៗ ចំនួន២៨ករណី ។

-បញ្ជូនឯកសារ និងព្រឹត្តិបត្រព័ត៌មាន ទៅក្រៅស្ថាប័ន ចំនួន៥២៩ច្បាប់ បានទទួលលិខិតចូលពីក្រៅស្ថាប័ន និងព្រឹត្តិបត្រព័ត៌មានចំនួន១៥៤២ច្បាប់។

-តាមដានការអនុវត្តបទបញ្ជាផ្ទៃក្នុង ត្រួតពិនិត្យការអនុវត្តផែនការការងារប្រចាំខែនីមួយៗនៅគ្រប់អង្គភាព និងបានត្រួតពិនិត្យប័ណ្ណចំណូល-ចំណាយទូទៅរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ។

**២.ទិសដៅការងារខែកុម្ភៈ ឆ្នាំ២០១៣**

-ត្រៀមរៀបចំសម័យប្រជុំពេញអង្គព្រឹទ្ធសភា ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ចំនួន២៖ សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាការពារជាតិ

-សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១១ ព្រមទាំងការផ្លាស់ប្តូរសមាជិកព្រឹទ្ធសភាដែលលាលែង។

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំ ជាមួយគណៈប្រតិភូបរទេស និងអង្គទូត។

-រៀបចំដំណើរការក្រុមភូមិភាគ ក្រុមសមាជិកា និងក្រុមអ្នកនាំពាក្យ របស់ព្រឹទ្ធសភា។

-ត្រៀមជួយសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួងនានា និងការចុះបេសកកម្មតាមបណ្តាខេត្តក្នុងរយៈវិស្សមកាលរបស់ព្រឹទ្ធសភា (ថ្ងៃទី៨កុម្ភៈ ៨ឧសភា ឆ្នាំ២០១៣) ។

-ចូលរួមក្នុងព្រះរាជពិធីដង្ហែ និងថ្វាយព្រះភ្លើងព្រះបរមរតនកោដ្ឋ, ត្រៀមបុណ្យទិវានារីអន្តរជាតិ បុណ្យខួបអនុស្សាវរីយ៍ឆ្នាំទី១ នៃនីតិកាលទី៣ ។

-ត្រៀមចូលរួមរៀបចំសិក្ខាសាលា និងវេទិកាក្នុង/ក្រៅព្រឹទ្ធសភា ព្រមទាំងក្នុង/ក្រៅប្រទេស ។

-ការអភិវឌ្ឍធនធានមនុស្សក្នុង/ក្រៅ ( ស្ថាប័ន/ប្រទេស ) វគ្គសិក្សាជំនាញវគ្គ ICT អាហារូបករណ៍ការសិក្សាភាសាបរទេស។

-ការខិតខំអភិវឌ្ឍន៍ និងបញ្ចូលបច្ចេកវិទ្យាព័ត៌មានទៅក្នុងការងារប្រចាំថ្ងៃ ការកសាងទិន្នន័យកម្មវិធីការបណ្តុះបណ្តាលជូនអ្នកឯកទេសខាង ICT នៅតាមអង្គភាព ( ការអនុវត្តគំរោងជំហានទី១ របស់ CAMSERV និងសហប្រតិបត្តិការល្អជាមួយក្រុមអ្នកឯកទេសវៀតណាម, ចិន ) ។

-គោលការណ៍អនុវត្តថវិកាឆ្នាំ២០១៣ និងនីតិវិធីអនុវត្តគោលការណ៍ អង្គភាពថវិកា និងការចំណាយតាមកម្មវិធី នីតិវិធី និងបែបបទលទ្ធកម្មសាធារណៈឆ្នាំ២០១៣, ការបង្កើតអង្គភាពលទ្ធកម្មសាធារណៈឯករាជ្យចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ។ ការចាប់ផ្តើមអនុវត្តគំរោងអភិវឌ្ឍន៍កម្មវិធី គណនេយ្យដើម្បីឆ្លើយតបកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ។

-បន្តជម្រុញការសាងសង់អគារ១៣ខ្នង ជំរុញភាគីចិននូវសំណើជំនួយសុំបន្ថែមពីរដ្ឋាភិបាលចិន, កសាង បែបបទ/នីតិវិធីដេញថ្លៃជណ្តើរយន្ត និងដំណើរការសិក្សាប្លង់គោល៤វិស័យ ( ប្រព័ន្ធលូ, ផ្លូវថ្នល់, ថាមពលព្រះអាទិត្យ, និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ) ការសិក្សាប្លង់មេ (ភាពយូរអង្វែងនៃការទទួលជំនួយ) បែបបទជំនួយពីរដ្ឋសភាវៀតណាម និងសាកលវិទ្យាល័យធុរកិច្ច និងបច្ចេកវិទ្យាល័យហាណូយ ។

-ការត្រៀមដំណើរការរៀបចំគម្រោងថវិកាតាមកម្មវិធី ( កំណែទម្រង់ថ្មីរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ) ។

-ការត្រៀមកសាងរបៀបវារៈ និងមាតិកានៃការសិក្សាស្រាវជ្រាវឆ្នាំ២០១៣ ខិតខំកែលំអទម្រង់របាយការណ៍សិក្សាស្រាវជ្រាវ និងរបាយការណ៍ផ្សេងៗ ។

-ការត្រៀមកសាងរបៀបវារៈ កម្មវិធី សកម្មភាព និងវេទិកានៅតាមភូមិភាគទាំង៨ និងសកម្មភាពរបស់ក្រុមផ្សេងៗក្នុងឆ្នាំ២០១៣។

-ការត្រៀមកសាងផែនការសកម្មភាព សមាហរណកម្មរបស់គណៈកម្មការទាំង៩ លើការបំពេញមុខងារទាំង៣ និងសហប្រតិបត្តិការអន្តរជាតិប្រចាំឆ្នាំ២០១៣ ។

-ការត្រៀមកសាងផែនការ និងកម្មវិធីបោះពុម្ព ផែនការ និងកម្មវិធីអភិវឌ្ឍ ICT ផែនការ និងកម្មវិធីការងាររបស់បណ្ណាល័យ បណ្ណសារដ្ឋាន រដ្ឋបាល និងសន្តិសុខឆ្នាំ២០១៣។

-រៀបចំបែបបទសម្រាប់ការចូលរួមមហាសន្និបាត IPU នៅទីក្រុង Quito ប្រទេសអេក្វាឌ័រ (ខែមីនា ឆ្នាំ២០១៣)៖ បទបង្ហាញអំពីព្រឹទ្ធសភា នីតិកាលទី៣ (សមិទ្ធផល និង ការប្រឈម)។

## ៣.សេចក្តីសន្និដ្ឋាន

នៅក្នុងខែមករា ឆ្នាំ២០១៣នេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាជាប់ជំពាក់នឹងការត្រៀមចូលរួមបុណ្យព្រះសពព្រះមហាវីរក្សត្រ ។ ដោយឡែកអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានយកចិត្តទុកដាក់ខ្ពស់លើការងារជាច្រើន ក្នុងការចាប់ផ្តើមជំហានថ្មី ជាពិសេសការត្រួតពិនិត្យមើលលើលទ្ធផលនៃការអនុវត្តថវិការបស់ព្រឹទ្ធសភាឆ្នាំ២០១២ និងការកំណត់គោលការណ៍ប្រតិបត្តិហិរញ្ញវត្ថុរបស់ព្រឹទ្ធសភា សម្រាប់ឆ្នាំ

២០១៣ និងការរៀបចំថវិកាតាមកម្មវិធីនៅគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមយុទ្ធសាស្ត្រកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈសំដៅជម្រុញឲ្យព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាមានការអភិវឌ្ឍសេវារបស់ខ្លួនឲ្យបានច្រើន ប្លែក លឿន ថ្មី ពេញចិត្ត ទុកចិត្ត និងទាន់ចិត្ត។

ភ្នំពេញ, ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៣

**អគ្គលេខាធិការ**

**អ៊ុំ សារិទ្ធ**